## Identifying items or people 1



### នៅក្នុងបណ្ណាគារ

និមល៖ នីតា ជួយមើលសៀវភៅពីរក្បាលនេះមើល មួយណាល្អជាង?

នីតា៖ ខ្ញុំឃើញអត់មានខុសគ្នាអីផង មួយណាក៏បានដែរ។

និមល៖ ក្របខាងក្រៅអ៊ំា មួយណាស្អាតជាង? មួយរូបផ្កា មួយរូបសត្វឆ្កែ។

នីតា៖ អូ ខុសតែក្របខាងក្រៅហ្នឹង។ យកអាមួយរូបផ្កានេះទៅអីចឹង ពណ៌ស្រស់ មើលទៅស្អាត។

### រកផ្ទះមិត្តភក្តិ

និមល៖ អាឡូ នីតា ខ្ញុំមកដល់មុខសាលាសន្ធរម៉ុកហើយ ផ្ទះនីតាឯងនៅណា?

នីតា៖ អូ និមលឯងជិះមកក្រោយសាលាម៉ោ ហើយរកមើលហាងបាយឈ្មោះពេញចិត្ត
ផ្ទះខ្ញុំនៅជិតហាងហ្នុង។

និមល៖ នៅខាងណាហាង? ផ្ទះពណ៌អីគេ?

នីតា៖ នៅទល់មុខហាងហ្នឹងម៉ង។ ផ្ទះពណ៌ស មានទ្បានពណ៌ខ្មៅចតនៅពីមុខ។

និមល៖ អូខេ ហ្នឹងហើយ ខ្ញុំជិះទៅរកសិន។ បើរកអត់ឃើញ ចាំតែទៅម្តងទៀត។

| | |
|---|---|
| និមល, នីតា | female Cambodian names |
| ក្បាល | classifier for books, as in: សៀវភៅពីរក្បាល = two books |
| អ៊ំា | emphatic particle |
| អាមួយ ... | the one with/which ... |
| អាឡូ | on the phone: hello! |
| សាលាសន្ធរម៉ុក | name of a school in Phnom Penh |
| ម៉ោ | spoken form of មក = to come |
| ហ្នុង | this, that |
| អីគេ | what |
| ទល់មុខ | opposite of, facing (each other) |
| ម៉ង | right away, directly |
| ហ្នឹងហើយ | ok, all right |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| បើរកអត់ឃើញ ... | if I don't find it ... |
| ចាំ ... | phrase-initial: I will [do] ... |
| តេ | to call (by phone), also: ខល, ទូរស័ព្ទ |

## Cultural notes

នៅប្រទេសកម្ពុជាមានទំនិញនាំចូលជាច្រើន ដូច្នេះ នៅពេលទិញទំនិញនៅផ្សារ ភាគច្រើនអ្នកទិញសួរអ្នកលក់ថាទំនិញនោះផលិតនៅប្រទេសណា។ ប៉ុន្តែ ពេលខ្លះ អ្នកទិញអាចសម្គាល់ឃើញពីភាពខុសគ្នានិងដឹងពីប្រភពទំនិញដោយខ្លួនឯង។ ឧទាហរណ៍ សម្រាប់សម្លៀកបំពាក់ គេសម្គាល់ទៅលើសាច់ក្រណាត់ រីឯស្បែកជើង គេសម្គាល់ទៅលើម៉ូតនិងសាច់ស្បែកជើង ប៉ុន្តែពេលខ្លះក៏ប៉ះចំទំនិញក្លែងក្លាយផងដែរ។

| | |
|---|---|
| នាំចូល | to import |
| ផលិត | to produce; to be produced |
| សម្គាល់ឃើញ | to notice |
| ប្រភព | source, origin |
| សាច់ក្រណាត់ | fabric, or generally the type of fabric |
| ម៉ូត | fashion, design |
| សាច់ស្បែកជើង | to type of shoe leather |
| ប៉ះចំ | to encounter |
| ទំនិញក្លែងក្លាយ | counterfeit goods |

## Additional dialogue

ម្តាយ៖ នីតា កូនឯងទៅយកកាបូបខ្មៅរបស់ម៉ាក់នៅក្នុងទូតិចម៉ោ។ កាបូបខ្មៅមានពីរអាំ។ យកអាមួយសំប៉ែតម៉ោណា។ អាធំ កុំយក។

នីតា៖ នៅក្នុងទូតូចជិតទូខោអាវហ្នឹងមែនម៉ាក់?

ម្តាយ៖ ហ្នឹងហើយ។ បើកទៅឃើញកាបូបខ្មៅពីរនៅខាងស្តាំហើយ។ មួយរាងសំប៉ែត ហើយលាត អត់មានរូបអីទេ។ យកអាមួយហ្នឹងម៉ោ។

| | |
|---|---|
| ម៉ាក់ | mom |
| ... តិចម៉ោ | softens a request |
| សំប៉ែត | flat |
| អាធំ | the big one |
| លាត | without design/pattern |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.